# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ប៉ែន សារ៉ុន ភេទ ប្រុស អាយុ ៧៤ឆ្នាំ
## រស់នៅភូមិ១ ឃុំកំពេញ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
## សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា, ឡុង ដានី និង ជី ទេរិទ្ធ
## ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១
## សរុបៈ ១៥ទំព័រ

សារ៉ុន : ៦ កាលនោះពូ កុងនៅជាមួយនឹងកងពលទី១ ក្រុងសីហនុ ហើយគេស្រាវជ្រាវខ្ញុំទៅ ខ្ញុំជាអ្នកបច្ចេកទេស អីចឹងគេឲ្យខ្ញុំនៅជាមួយពួកកងទ័ព ចល័ត ម្នាក់នេះមួយទៀត ឈ្មោះ ជា គ្រៀន ។

ដារ៉ា : គាត់នៅរស់ដែរ?

សារ៉ុន : គាត់នៅរស់ដែរ ប៉ុន្តែពេលគាត់ខ្ចីទេ ព្រោះអត់មានដូចកុង ព្រោះកុងដើរឆ្ងាយជាង វា ចល័តតែនៅនេះទេ កុងដើរតាមខេត្ត ហើយបកក្រោយមកវិញ ចង់ជំរាបថាទីតាំង នៅនេះ ឆ្នាំ១៩៧៦នេះជាតំបន់ជំរករបស់ខ្មែរក្រហម មុននឹងប្រហែលជាឆ្នាំ៥៨-៥៩ នោះ ៥៨, ៥៧, ៥៦ ហ្នឹងវាកកើតកូនចៅនៅហ្នឹងហើយណា៎ ដែលមានប៉ូឃាយម៉ឺ នេះ មួយដែលជំរករបស់វា តាមខ្ញុំដឹង ។ ក្នុងឆ្នាំ៧៦ហ្នឹង ខ្ញុំបានមកចូលរួមបច្ចេកទេស ដឹកជញ្ជូន ។

ដារ៉ា : ក្រុមដឹកជញ្ជូនអីនេះ?

សារ៉ុន : ក្រុមដឹកជញ្ជូនហ្នឹងរយៈពេលខ្ចីទេ ទៅយកថ្មីពីនេះ ជំនឹកនេះ ភ្នំនេះ ។

អ្នកជិតខាងៈ អីចឹងសាក់ឡូមកផង សាក់ឡូអត់ដូនទៅមើលរណ្តៅវាដឹក ។

សារ៉ុន : រណ្តៅហ្នឹងហើយមានខ្ញុំបានទៅយក អា PH ចិនប្រើ មិនមែនប្រើកាបទេ ប្រើប្រវ៉ាក់ ដែលមានកំលាំងសេសវ៉ា៨០០ជាងសេស ខ្ញុំបានទៅយកពីពោធិ៍សាត់មក មកចាប់ថ្ម នេះដាក់ឡាន ។ កាលជំនាន់នោះអត់មានឡានប្រភេទណាទេ មានតែឡានអាមេរិកហៅ អះគ្រា អះគ្រាហ្នឹងសំរាប់ដឹកថ្មបែន ទំងន់វ៉ា៥តោនឡានទទេ ហើយបន្តមក ទៀតចប់ រឿងទំនប់ហ្នឹង វាធ្វើទិសដៅវាគ្រប់ចំនួនហើយ តែនៅខ្វះអក្សរ T វាចាក់ T អីចេះ T ទៅនេះទៅ៥០ មកនេះ៥០ ហើយពីដៃទំនប់រលក... អាហ្នឹងចាក់មក៥០ ដែរ ទុកចន្លោះ៥០ វាធ្វើអ៊ូកន្លែងនេះ កប៉ាល់ចូលកន្លែងនេះ អីចឹងដែនការរបស់វាអត់ ទាន់ហើយ ។ ៧៦ប្រហែលជាខែ១ហ្នឹង។ ប្រហែលថ្ងៃ១០ ឬថ្ងៃ៧-៨ ខ្ញុំចាប់ផ្តើម

សាងសង់ផ្លូវហ្នឹង មានចិន មានខ្ញុំ មានកងកំលាំង បច្ចេកទេសចិន ហើយខ្ញុំនេះក៏ចូលរួមជាមួយគេទេមិនមែនជាជំនាញអីខ្លាំងណាស់ណាទេ ប៉ុន្តែចូលជាមួយគេ ទី១ក្រាស់សេចាក់ដោយគ្រឿងចក្រឈូសផ្លូវ អាប៉ិល យើងហ្នឹងមានដេរីតមាន៦គ្រឿង ហើយអាដេស៊ីសប្រើកាត អត់មានឯកលិច អត់មានបូមទេ អារឹរពន់វាអត់មានបូម ប្រើកាតអាហ្នឹង៦គ្រឿង ហើយរ៉ូឡូជាន់ហ្នឹងវាមាន១២ វាបុក៦ខែហើយ ខែ១ ខែ៦ចប់ ផ្លូវពីហ្នឹង ទៅដល់រោងចក្រប្រេងកាតចំងាយបើខ្ញុំមិនភ្លេច ពី......។

ដារ៉ា : ៦ខែហើយ ។

សារ៉ុន : ៦ខែហើយ ។......... មានកូន៤នាក់ ហើយយាយខ្ញុំគាត់ស្បែកស គាត់កូនកាត់ កាត់ចិន-វៀតណាម ខ្ញុំអត់បានជួបទល់ថ្ងៃនេះ វាមានអារម្មណ៍ថ្មីមិននៅ ចល័តកោះកុង កំពតតាកែវ កំពង់ស្ពឺ ទីតាំងធំសម្ភារៈនៅភ្នំពេញ ហើយខ្ញុំមានឡានអំមីសៀងមួយមានម៉ាស៊ីនក្រឡឹង ម៉ាស៊ីនផ្សារ កាលណាត្រូវការកាត់ស្ពាន កាត់ ត្រូវការឡានដំឡើង១ចូលរួមជាមួយគេ អីចឹងយាយខ្ញុំមុនហ្នឹង ស្មាទោសលោកគ្រូមេឃុំអត់ដឹងដែរ ប៉ុន្តែទើបដឹងក្រោយទេ មានសតិអារម្មណ៍វាយកទៅចាក់ថ្នាំសម្លាប់នៅពេទ្យចម្ការ ចេកហ្នឹងទាំងអស់ ២២នាក់ ។

ដារ៉ា : គឺទាក់ទងស្អីដែរបាន?

សារ៉ុន : ហ្នឹងវាសតិអារម្មណ៍អត់ធ្វើការ ប្រើទៅដូចថាមិនចង់ទៅ ប្រកែកអីចឹងទៅ ឬក៏អារម្មណ៍មិនល្អធ្វើការមិនកើតអីចឹង អីចឹងវាយកទៅដេកពេទ្យ ដេកពេទ្យងាប់តែម្តង ។

ដារ៉ា : ពេទ្យនៅចម្ការចេក?

សារ៉ុន : ពេទ្យនៅចម្ការចេក ។

ដារ៉ា : នៅក្នុងស្រុកអី ឃុំអីអ៊ំ?

សារ៉ុន : អាហ្នឹងក្រុងកំពង់សោម ។

អ្នកជិតខាងៈ រាល់ថ្ងៃពេទ្យយើងរាល់ថ្ងៃ ពេទ្យបង្អែកខេត្តព្រះសីហនុ អតីតប្រវត្តិកុង ។

សារ៉ុន : ហើយអីចឹងដីទឹកនេះ ខ្ញុំមកលើកទី១ ខ្ញុំមកអីចឹង ។ លើកទី២ខ្ញុំមកធ្វើមេឃុំហ្នឹងទៀត ឆ្នាំ៨៤ ខែ៦ ផ្លាស់មកនេះ គេហៅថាសង្កាត់៤ ឃុំកំពេញហ្នឹង កាលមុនគេដាក់សង្កាត់តែខ្ញុំធ្វើចៅសង្កាត់លេខ៤ ក្រុងព្រះសីហនុទេ ហើយដល់៨៦បានផ្លាស់មកនេះ ។ ហើយយកក្នុយ ។

អ្នកជិតខាងៈ មេឃុំ៤ជំនាន់ មេឃុំចាន់ មឿន អាណត្តិទី១....។

ដារ៉ា : អ៊ំនៅជាក្នុងកងបច្ចេកទេសគេហ្នឹង គេមានមេកង មានអី?

សារ៉ុន ៖ មាន ។

ដារ៉ា ៖ មានចាំឈ្មោះខ្លះទេ?

សារ៉ុន ៖ មិនចាំទេ បើមេហ្នឹងគ្រាន់តែមានចាំតែឈ្មោះ ប៉ុន្តែមុខមិនដែលឃើញទេ ។

ដារ៉ា ៖ មេឈ្មោះអីទៅ?

សារ៉ុន ៖ មេ មាស មុត ។

ដារា ៖ មាស មុត ហ្នឹងម៉ង?

សារ៉ុន ៖ បាទ! កងពលទី១ ។

ដារ៉ា ៖ គាត់គ្រប់គ្រងផ្ទាល់នៅហ្នឹងតែម៉ង?

សារ៉ុន ៖ បាទ! គ្រប់គ្រងកងពលទី១ នៅកំពង់សោម ប៉ុន្តែពួអត់ដែលឃើញមុខទេ លឺតែតាមខ្សែរយៈកងទ័ពអីចឹង ។

ដារ៉ា ៖ នៅកំពង់សោមគេហៅកងពលទី១អីចឹងម៉ង?

សារ៉ុន ៖ កងពលទី១ បាទ ។

ដារ៉ា ៖ ជាទាហានអំ?

សារ៉ុន ៖ អាហ្នឹងទាហានហើយ កងទ័ព ។

ដារ៉ា ៖ អីចឹងមានតែក្រុមមកធ្វើកំពង់ផែហ្នឹង យកពីទ័ពកងពលទី១មកតែម៉ង ។

សារ៉ុន ៖ បាទ! យកប្រជាជនឈ្លើយសឹកយើងដូចជាល្មមៗអីចឹងទៅ មានបញ្ហា មានវិបត្តិអីផ្សេងៗ យកមកលត់ដំកន្លែងហ្នឹង ស្លាប់ក៏ស្លាប់ទៅ អីក៏អីទៅ ។

ដារ៉ា ៖ អីចឹងបើនិយាយទៅកាលដែលមានសតិអារម្មណ៍ ជាមួយគ្រួសាររបស់កុង ដែលថាមានស្រីៗប៉ុន្មាន២០នាក់អំអី?

សារ៉ុន ៖ បាទ! ២០នាក់ ។

ដារ៉ា ៖ ដែលបញ្ជូនទៅចម្ការចេកហើយ ចុងក្រោយ ។

សារ៉ុន ៖ ហ្នឹងសុទ្ធតែគ្រួសារមន្ត្រីរាជការ ហើយប្តីៗផ្ទាស់ទៅនេះ ដូនវាថាផ្ទាស់ តែតាមការពិតយកទៅវ៉ៃចោលទេ មនុស្សកាលណាមានសតិអារម្មណ៍ ការងារមិនពេញដៃទេ ។

ដារ៉ា ៖ ហ្នឹងនៅតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត ដដែរ?

សារ៉ុន ៖ របស់ មាស មុត ដដែរ ដល់ចប់ដែនការរបស់វា ខ្ញុំទៅបង្រៀនក្បួរនៅស្ទាច់ដែងហ្នឹង ២ខែ ចប់ការងារសាងសង់ស្ពានផ្លូវទៅអណ្តូងទឹក កន្លែងចិនយំ កន្លែងបត់អន្ទង់អាំង កន្លែងអូរស្ទាច់ ។

អ្នកជិតខាង៖ ខេត្តកោះកុង?

សារ៉ុន ៈ កោះកុង ហ្នឹងខ្ញុំធ្វើ៣ខែ ចប់អាហ្នឹងហើយខ្ញុំមកវិញ ៧៧ ខែ១០ផ្លាស់ខ្ញុំហើយ ចប់ការងារវាផ្លាស់ខ្ញុំ ។

ដារ៉ា ៈ ៧៧អ៊ី?

សារ៉ុន ៈ ៧៧យកខ្ញុំទៅរៀបជាមួយយាយសព្វថ្ងៃនេះ រៀបហើយផ្លាស់ខ្ញុំទៅវ៉ៃចោលនៅកោះស្លាដដែរ ។

អ្នកជិតខាង ៈ ទៅតាកែនកោះស្លា?

សារ៉ុន ៈ តាកែនកោះស្លាដដែរ ។

អ្នកជិតខាង ៈ គាត់សុទ្ធតែជាអ្នកអតីតមន្ត្រីរាជការជំនាន់សម្ដេចឳ ។ ឳពុកខ្ញុំសុទ្ធតែជំនាន់ហ្នឹងជាមួយគាត់ ។

ដារ៉ា ៈ កាលពីជំនាន់សម្ដេចឳ ។

សារ៉ុន ៈ ឳពុកពួកម៉ាក់ខ្ញុំ ក្បែម្រ៉ាក់លេខ១ សឹងតែថាស្រក់ទឹកភ្នែកមិនទាន់បាត់ផង ព្រោះវាប្រឡូកការងារជាមួយគ្នា គាត់ជាងដែរ កំសត់ណាស់ប៉ុន្មានជំនាន់ហ្នឹង ។

ដារ៉ា ៈ ចុះអ៊ំធ្វើម៉េចបានចូលមកធ្វើកងពលទី១ ក្រោមការគ្រប់គ្រងរបស់ មាស មុត បាន?

សារ៉ុន ៈ ដើមឡើយខ្ញុំនៅចៅសង្កាត់ ។

អ្នកជិតខាងៈ អត់ទេនិយាយជំនាន់ប៉ុលពត ។

ដារ៉ា ៈ ជំនាន់ប៉ុលពត មុននឹងចូលមកដល់កងពល១ហ្នឹង?

សារ៉ុន ៈ មុននឹងចូលបម្រើការងារវាហ្នឹង កាលនោះខ្ញុំនៅក្នុងបច្ចេកទេស SKD គ្រប់គ្រងបច្ចេកទេសម៉ាស៊ីន ។

ដារ៉ា ៈ មិនមែនផលិតស្រាទេ?

សារ៉ុន ៈ ពីឆ្នាំ៦០ដល់ឆ្នាំ៧០ ។

ដារ៉ា ៈ ផលិតស្រាមែនអ៊ំ SKD?

សារ៉ុន ៈ ផលិតស្រា ដល់ឆ្នាំ៧០គេស្រាវជ្រាវរកអ្នកប្រវត្តិមានទ្រឹស្ដី អក្សរលំនាំអីបានសរសេរមើលបានអីចឹង បារាំង ខ្មែរខ្វះអីចឹងទៅ ចៅហ្វាយក្រុងចាស់ឈ្មោះ យ៉ែម មុន្នីរ័ត្ន បានទៅធ្វើប្រជាមតិ ប្រជាធិបតេយ្យនៅក្នុងរោងចក្រហ្នឹង ទាំងអស់៤៤០នាក់ ធ្វើជាមតិជ្រើសរើសចៅសង្កាត់ថ្មីមួយ ដឹកនាំប្រជាជនភៀសសឹកមកពីតំបន់ខ្មាំង ដល់ធ្វើទៅជាប់ខ្ញុំដល់ជាប់ខ្ញុំ ខ្ញុំត្រូវធ្វើការ២កន្លែង ចៅសង្កាត់ផង គ្រប់គ្រងបច្ចេកទេសម្ដងម្កាលនៅសហគ្រាសផង ឃើញទេ។ ហើយមានពួកម៉ាក់មួយរៀនជាមួយគ្នា ជាមួយ អុក

ចាន់ រាល់ថ្ងៃរដ្ឋមន្ត្រី អុក ចាន់ ហ្នឹងណា រដ្ឋលេខាហ្នឹង រៀនថ្នាក់ជាមួយខ្ញុំដែរ មានមួយទៀតបែកចិត្តទៅធ្វើអាពត ។

ដារ៉ា : ឈ្មោះអីទៅអ៊ំ?

សារ៉ុន : ឈ្មោះវាច្រើន កាលនេះឈ្មោះគេហៅ អាចារ្យលឹម។ កាលជំនាន់ហ្នឹង ដល់ក្រោយមកវាដឹងថាខ្ញុំនៅនេះ វាសមាជិកកងពលនិរតី តែមិនដឹងកងពលប៉ុន្មានទេ ដល់វាដឹងថាខ្ញុំនៅនេះ ៧៥វាមកដល់មុនគេ មកដល់ស្រាវជ្រាវឃើញកុងនៅហ្នឹង ជម្លៀសកុង ហើយវាចាត់ចែងកុងឲ្យធ្វើបច្ចេកទេសអីចឹង ឃើញទេ ដល់អីចឹងទៅដឹងថាខ្ញុំធ្វើចៅសង្កាត់ដែរ ដល់អីចឹងទៅក៏វាទុកខ្ញុំហ្នឹងទៅ ទុកឲ្យបម្រើការងារជាមួយកងទ័ពអីចឹងទៅ ហើយអីចឹងខ្ញុំកាលជំនាន់៧០មក៧៥ហ្នឹង វា២កន្លែង ចៅសង្កាត់ផង ហើយម្នាងបច្ចេកទេសផង ហើយដឹកនាំចៅហ្វាយក្រុងមាន យ៉ែម មុន្នីរ័ត្ន មានអនុរង អ៊ី ឈា ។

ទេវិទ្ធ : គាត់ទាំង២នាក់ហ្នឹង?

សារ៉ុន : ២នាក់ហ្នឹងចៅហ្វាយក្រុងហ្នឹងស្លាប់អស់ហើយ គាត់ចាស់ៗដែរហើយ មិនដឹងទៅណាអស់ហើយ ។

ទេវិទ្ធ : អត់បានព័ត៌មានគាត់?

សារ៉ុន : កាលហ្នឹងខ្ញុំអាយុ២០ ឆ្នាំ៦០ហ្នឹង ។

ទេវិទ្ធ : អ៊ំកំពង់ដែហ្នឹង បើតាមអ៊ំដឹងចាប់ផ្តើមសង់ឆ្នាំណាដែរ?

សារ៉ុន : ៧៦ ។

ទេវិទ្ធ : គេចាប់ផ្តើមធ្វើ?

សារ៉ុន : បាទ!

ទេវិទ្ធ : ប្រហែលជាខែណាដែរ?

សារ៉ុន : អេ៎ ខ្ញុំមិនបានចាំទេ ព្រោះខ្ញុំមកគេធ្វើខ្លះហើយហ្នឹង ប្រហែលជាខ្ញុំមកខែ១ ឬខែ៤ ឬខែ៥ប៉ុណ្ណឹង ឬក៏ខែ មើលខ្ញុំធ្វើថ្នល់ខែ៦ អូហ៎ខែ២ ខ្ញុំមកដល់ហ្នឹងខែ២ ខែ២មានគេធ្វើខ្លះហើយ

ទេវិទ្ធ : អីចឹងអាចគេចាប់ធ្វើមុនហ្នឹង?

សារ៉ុន : មុនហ្នឹង បែកហើយមកដល់ហ្នឹងតែម្តងអាពត ។

ទេវិទ្ធ : ពេលដែលគោលបំណងធ្វើកំពង់ដែហ្នឹង អ៊ំដឹងទេថាគេធ្វើដើម្បីអី?

សារ៉ុន : ធ្វើដឹកជញ្ជូន ។

ទេវិទ្ធ : ដឹកជញ្ជូនកំប៉ាស់ ។

សារ៉ុន ៖ បាទ! ដឹកជញ្ជូន ។

ដារ៉ា ៖ មានកំពង់ផែក្រុងព្រះសីហនុយើងមួយដែរ?

សារ៉ុន ៖ អាហ្នឹងមានមួយដែល អាហ្នឹងគេសំរាប់ទីក្រុង អានេះធ្វើចល័តអីរបស់របរតូចតាច ហើយកុងមិនដឹងថាគោលបំណងគេធ្វើអីដែរ គ្រាន់តែដឹងថាទំនប់ហ្នឹងធ្វើផែ ។

ទេរិទ្ធ ៖ ពេលធ្វើហ្នឹង ប្រធានការដ្ឋានសាងសង់កំពង់ផែនេះ អ៊ំស្គាល់ឈ្មោះគេទេ?

សារ៉ុន ៖ លឺសូរឈ្មោះដែរ ដឹកនាំនៅកន្លែងនេះមានឈ្មោះ ឌឹម នេះ១, នង ឆាន ហ្នឹង២ ប៉ុន្តែ នង ឆាន ហ្នឹងខ្ញុំមកនៅបានប្រហែលជា២ខែគាត់ក្បត់ ។

ទេរិទ្ធ ៖ គេចាប់?

សារ៉ុន ៖ បាទ! គេចាប់ នង ឆាន កូនតា នង សួន ហ្នឹង អ្នកនយោបាយចាស់ហ្នឹង ដល់ក្រោយ មកគាត់រត់ រត់យក PCS ទៅបាត់ទល់សព្វថ្ងៃ ។

ដារ៉ា ៖ នង ឆាន កូន នង សួន ។

សារ៉ុន ៖ បាទ! គាត់នៅក្នុងកងពលហ្នឹងដែលតាមមើល ។

ទេរិទ្ធ ៖ ពេលដែលគេចាប់គាត់ទៅ អ្នកដែលមកជំនួសទៅពីណាគេវិញ?

សារ៉ុន ៖ អត់ដឹងទេ ខ្ញុំចេញផុតហើយ ។

ទេរិទ្ធ ៖ អីចឹង?

សារ៉ុន ៖ បាទ! ខ្ញុំចេញផុតហើយ ។ ខ្ញុំចេញផុតហើយ ខ្ញុំគេយកទៅកោះស្លាហើយ ។

ទេរិទ្ធ ៖ អ្នកដែលមួយទៀត ឌឹម ហ្នឹងស្អីគេ ឌឹម?

សារ៉ុន ៖ ឌឹម ហ្នឹងនៅក្នុងជួរកងពលដែរ ។

ទេរិទ្ធ ៖ ឈ្មោះអី ឌឹម?

សារ៉ុន ៖ អត់ដឹង ។

ទេរិទ្ធ ៖ កងពលលេខ១ដូចអ៊ំដែរ?

សារ៉ុន ៖ បាទ! ប្រហែលនៅក្នុងជួរកងពលហ្នឹងដែរ ។

ទេរិទ្ធ ៖ ឋានៈអី?

សារ៉ុន ៖ ការងាររវា អាហ្នឹងវាបន្ទាប់គ្នា ដូចថាមេប្រធាន មាស មុត អីចឹងទៅ តមក នង ឆាន អីចឹង តាឌឹម អីចឹងទៅ ប៉ុន្មាននាក់ខ្ញុំនគាត់ ។

អ្នកជិតខាងៈ រហស្សនាមគេទេ?

សារ៉ុន ៖ បាទ! រហស្សនាមគេ មិនដឹងឈ្មោះអីទេ ។

ទេរិទ្ធ ៖ មិនមែនឈ្មោះទេអ៊ំ?

សារ៉ុន ៖ បាទ!

ទេរិទ្ធ ៖ ដែលអ៊ំដែលស្គាល់មុខអី ឌឹម ?

សារ៉ុន ៖ អត់ទេ និយាយរួមយើងមិនដែលឃើញមុខលោកធំ ។

អ្នកជិតខាង៖ ចាំជូនគាត់ទៅមើលកន្លែងមុខពេទ្យកុងទៀវ ។

សារ៉ុន ៖ មុខពេទ្យកុងទៀវកន្លែង ។

អ្នកជិតខាង៖ នៅលើហ្នឹងមានមួយទៀត ។

ដារ៉ា ៖ អីចឹងអ៊ំនៅក្នុងមួយការដ្ឋាននេះ មានទាំងកងទ័ពខ្មែរក្រហម ទាំងជនឈ្លើយសឹក ប្រជាជនអីប៉ុន្មាននាក់?

សារ៉ុន ៖ មិនដឹងទេចៅ អត់ដឹង យើងអត់យកចិត្តទុកដាក់ ។

ដារ៉ា ៖ តែអ៊ំឃើញជាហ្វូងមនុស្ស?

សារ៉ុន ៖ ច្រើន បាទច្រើន ។ ឡានដឹកជញ្ជូនខ្សាច់ ថ្ម យកពីកំពង់ត្រាច ខ្ញុំរត់មួយថ្ងៃធ្វើម៉េចឲ្យបាន៣ជើង ។

ដារ៉ា ៖ យកខ្សាច់ពី?

សារ៉ុន ៖ យកថ្ម ។

ដារ៉ា ៖ យកថ្មពីកំពង់ត្រាច?

សារ៉ុន ៖ យកអាវ៉ែកយើង យកមកចាក់នៅក្នុងពំនូកខ្សាច់ ពំនូកថ្មហ្នឹង មួយថ្ងៃ៣ជើង ម៉ោង៣ចេញទៅធ្វើម៉េចឲ្យបាន៣ជើងមួយថ្ងៃ ។ មួយថ្ងៃគឺប្រជុំមួយថ្ងៃ ថ្ងៃហ្នឹងប្រជុំមួយថ្ងៃ មូលហេតុដែលអត់បាន៣ជើងមូលហេតុអី ។

ដារ៉ា ៖ បើសិនជាអត់បាន៣ជើង?

សារ៉ុន ៖ បើអត់បាន៣ជើង ឡានខូច បែកកង់អីចឹងទៅ ។

ដារ៉ា ៖ ៣ជើង បើនិយាយទៅ ដឹកខ្សាច់ ដឹកបាន២ឡាន ។

សារ៉ុន ៖ បាន ។

ដារ៉ា ៖ អេ៎ ៣ជើងត្រឡប់ទៅមក ៦ជើង ។

សារ៉ុន ៖ ទៅមក៣ជើង ជួនអីម៉ោង១១ ឬម៉ោង១បានមកដល់ អាជើងទី៣ បាយជួនអីវា បបរមួយវែកដឹងស្រាប់ហើយចៅអើយ សែនមហាលត់ដំហើយកុង លត់ទាល់តែណាណី លត់ទាល់តែបែកប្រពន្ធបែកកូនអស់ ។

ទេរិទ្ធ ៖ អ៊ំនៅធម្មតាខ្មែរក្រហមវាយកយើងមកធ្វើការអីចឹង ឧទាហរណ៍អ្នកធ្វើការខ្ជិលច្រអូស អ្នកធ្វើខុស អ្នកធ្វើអីចឹង វាមានមន្ទីរវាអីយកកន្លែងអប់រំអី?

សារ៉ុន ៖ មានកន្លែងអប់រំ តែយើងអត់ដែលឃើញទេ គ្រាន់តែបាននិយាយថា ផលូវមិត្តនេះខុសឆ្គង ហើយសួរថាទៅណា មិត្តក គេយកទៅអប់រំ ពេលដែលអប់រំគឺបាត់ហើយ ។

អ្នកជិតខាង៖ របស់សំណាកដែលវានៅសល់ច្រើន មិនមែនតែកន្លែងយកថ្មទេ មានអាងទឹកធំ១២ទៀតនៅក្នុងឃុំខ្ញុំដែរ អាងប៉ុលពតធ្វើតែម្តងសំរាប់វាយកទឹកមកប្រើប្រាស់ បន្តិចចាំជូនគាត់ទៅមើល នៅ១២ក្បៀសនោះក៏អាងដែរ វាបូមមក អ្វីដែលសាកសល់ជាភស្តុតាងសំរាប់យើង ថាជារបស់ប៉ុលពតកសាង ។

ដារ៉ា ៖ អ៊ំចង់សុំស្គាល់ឈ្មោះលោកអ៊ំ មុិញនិយាយទៅអត់សួរលោកអ៊ំម្តងទៀត?

សារ៉ុន ៖ ខ្ញុំឈ្មោះ ប៉ែន សារ៉ុន ។

ដារ៉ា ៖ ហើយអ៊ំមានព្រះជន្មប៉ុន្មានហើយអ៊ំ?

សារ៉ុន ៖ ខ្ញុំ៧៣, ៧៤ហើយ ។

ដារ៉ា ៖ ហើយសព្វថ្ងៃអ៊ំមានរបរអីដែរ?

សារ៉ុន ៖ សព្វថ្ងៃខ្ញុំមន្ត្រីរាជការហ្នឹង គេឲ្យចូលនិវត្តន៍ពី៥៥ តែសព្វថ្ងៃគេទុកឲ្យខ្ញុំបម្រើការងារជាប្រធានការិយាល័យកណ្តាល ។

ដារ៉ា ៖ ប្រធានការិយាល័យ?

សារ៉ុន ៖ ប្រធានការិយាល័យសាធារណៈការ ។

ដារ៉ា ៖ សាធារណៈការនៅស្រុកនេះ?

សារ៉ុន ៖ បាទ! នៅស្រុកហ្នឹងតែម៉ង ។

ដារ៉ា ៖ ស្រុកស៊ឹងហាវ?

សារ៉ុន ៖ បាទ! សួរតែក្លួយដឹងហើយ ។

ដារ៉ា ៖ ហើយអាស្រ័យដ្ឋានអ៊ំ ភូមិអី ឃុំអីដែរ?

សារ៉ុន ៖ ខ្ញុំនៅហ្នឹង មណ្ឌល១ ភូមិ១ ឃុំកំពេញ ។

ដារ៉ា ៖ ភូមិ១ ឃុំកំពេញអីចឹង?

សារ៉ុន ៖ បាទ!

ដារ៉ា ៖ ស្រុកស៊ឹងហាវ ខេត្តព្រះសីហនុ?

សារ៉ុន ៖ បាទ! ខ្ញុំមកនៅនេះហាសិបជាងឆ្នាំ ។

ដារ៉ា ៖ ហាសិបជាងឆ្នាំហើយអ៊ំ?

សារ៉ុន ៖ បាទ! មកនៅហ្នឹង ស្រុកកំពង់សោម ហាសិបជាងឆ្នាំហើយ ពីខ្ញុំឈប់ពីការសិក្សាខ្ញុំប្រឡងមេព្រៃឆ្នាំ៥៨ ស៊ីវិការ៥៧ ទៅប្រឡងមេព្រៃគេឲ្យជាប់ចំណាត់ថ្នាក់តូតាល

អាលេខ១ ដល់លេខ១០គេមានក្របខ័ណ្ឌអេតាសុល ពីលេខ១១-១៥អាហ្នឹង ស្តាំ៦ ខែ តែកុងអត់បានធ្វើទេ ទៅស្តារនៅកំពង់ចាមនោះ អាបួនចុះចុងជប់ទៅបាន២ខែដែរ ចុះពីថ្នល់ជាតិទៅវា២២គីឡូ ហើយអត់មានទេថ្មើរជើង ស្តាយបន្ទិច ស្តាយអន្តរទៅ រហូតកាលជំនាន់ហ្នឹង ហើយរត់មកសំរាកសេរីអេសមេស្រូនេះ គេចាប់ផ្តើមដើរ ខ្ញុំចាប់មកដាក់ ឌើម៉ង់ធ្វើការជាមួយគេនេះ ជាប់ទាំង២កន្លែង ។ SKD ក៏ជាប់ អារោងចក្រប្រេងកាតក៏ជាប់ ហើយសព្វថ្ងៃមានពួកម៉ាក់មួយឈ្មោះ រាំង ចែន អាហ្នឹង ក្មើម្រ៉ាក់ខ្ញុំដែរ ។

ដារ៉ា : គាត់ធ្វើអី?

អ្នកជិតខាង: គាត់នៅកំពេញចាស់ឥលូវ ។

សារ៉ុន : ឥលូវគាត់រីក្រែតហើយលោកគ្រូ ។

អ្នកជិតខាង: តាចាន់ មិនទាន់ស្លាប់ណា៎?

សារ៉ុន : នៅទេ ៗ ។

អ្នកជិតខាង: ជិតក្រាស់ដែរ

សារ៉ុន: ហើយជាប់គ្នារហូត ទៅរៀនសាលានយោបាយអី ចងពលជាមួយគ្នាទៀត ចែន ហ្នឹង ។

ដារ៉ា : អ៊ំមានប្រសាសន៍ពីខាងដើមថាមានមិត្តភក្តិម្នាក់ដែរ ដែលចូលរួមធ្វើការដ្ឋានថ្មហ្នឹងដែរ ។

សារ៉ុន : បាទ! អត់ទេ គាត់ហ្នឹងអត់ដែលធ្វើថ្មទេ មានតែមូតម្កាលទេមកជាមួយខ្ញុំ ខ្ញុំជាអ្នក បើកឡានមកហ្នឹង ឡានអង្គជាងមានម៉ាស៊ីនផ្សា ម៉ាស៊ីនក្រឡឹងហ្នឹង មកជាមួយខ្ញុំ ឈ្មោះ ជា គ្រៀន នេះ ។

ដារ៉ា : ជា គ្រៀន?

សារ៉ុន : ជា គ្រៀន បាទ! គាត់ចាស់ហើយឥលូវ បើកឡានជាមួយតារោងចក្រធ្វើជីនោះ ហ្នឹងមកធ្វើមូតម្កាល ។

ដារ៉ា : ចង់ជួបគាត់ថាតើការធ្វើមូតម្កាលរបស់គាត់អីចឹង តើគាត់សង្កេតឃើញយ៉ាងម៉េច នៅក្នុង ទិដ្ឋភាពជំនាន់ហ្នឹង?

សារ៉ុន : ដូចជាមិនទេ គាត់ហ្នឹងរិតតែអត់ចេះនិយាយ ។ សួរមិនចេញ មិនមែនមិនចង់ឲ្យជួបទេ ដឹងតែតាមតែខ្ញុំដែរ ។

អ្នកជិតខាង: តែគាត់ច្បាស់ ព្រោះគាត់ធ្លាប់នៅនេះ ។

សារ៉ុន : ហើយខ្ញុំហ្នឹងមិនមែនសួរត្រឹមតែលោកចៅទេ អង្គការចៅក្រមតុលាការកាត់ទោសខ្មែរ ក្រហម ក៏មកសួរកុងដែរ ។

ដារ៉ា ៖ អីចឹងអេ!

សារ៉ុន ៖ បាទ!

ដារ៉ា ៖ អញ្ជើញមកសួរលោកអ៊ំហើយ?

សារ៉ុន ៖ មួយឃ្លាឆ្ងិតមេដាយមួយៗ តែចុងក្រោយទិសដៅគេចង់សួរមេហ្នឹងដែរ ប៉ុន្តែខ្ញុំថាលឺតែឈ្មោះទេ មិនដែលស្គាល់ អត់ដែលស្គាល់មែន ព្រោះយើងក្នុងនាមជាកម្មករហ្នឹង យើងទៅគិតគូរអីចឹង សុំតែមួយរស់ ។

ដារ៉ា ៖ ហើយអីចឹងអ៊ំបានខាងតុលាការមកស៊ើបហើយ?

សារ៉ុន ៖ បាទ! មានទាំងឆ្ងិតមេដាយ មានក្រដាសស្នាមហើយស្រាប់ ប៉ុន្តែក្រោយមកខ្ញុំផ្តាំដែលខ្ញុំថាបើសិនជាហៅខ្ញុំទៅតុលាការអី ចម្លើយចេះចុះខ្ញុំអត់ទៅ ព្រោះខ្ញុំអាយុប៉ុណ្ណេះ ។

ដារ៉ា ៖ អីចឹង?

សារ៉ុន ៖ បាទ! ខ្ញុំថាខ្ញុំអត់ទៅ ។

ដារ៉ា ៖ មូលហេតុអីដែលអ៊ំមិនទៅ?

សារ៉ុន ៖ មិនទៅ មិនចង់ទៅ ដោយសារ មិនដឹងជាអ្នកណាផងប្រាប់មកពីភ្នំពេញ ពីក្រុងអីមក ថាខ្ញុំនៅហ្នឹង ហើយខ្ញុំលាក់ម៉េចកើត គេប្រាប់អីចឹង មិនដឹងមូលហេតុសោះ យើងមិនមែនរឿងតុលាការអីចឹងស្អប់តែម្តង (សើច) ។

ដារ៉ា ៖ ហេតុអីបានអីចឹងអ៊ំ?

សារ៉ុន ៖ ស្អប់វា ខ្ជិល កុំឲ្យវាមាន មនុស្សឡើងតុលាការមិនសូវល្អប៉ុន្មាន សួរនាំ ។

អ្នកជិតខាង៖ តុលាការកាត់ទោសខ្មែរក្រហមវាផ្សេង តុលាការក្រុងយើងនេះ ។

សារ៉ុន ៖ មិនចូលចិត្តតែម្តង មិនឲ្យមានឈ្មោះ តែមិនដឹងធ្វើម៉េច គាត់ឆ្លើយថា ចៅក្រមហ្នឹង គាត់ថា អ៊េ! ទៅឲ្យលុយ មួយថ្ងៃយ៉ាងតិចក៏១០០ ឬក៏ជិតសិបជាងអីដែរ ។ ខ្ញុំថាអត់ទេ ២០០ក៏ខ្ញុំអត់ទៅ ។

ដារ៉ា ៖ ចៅក្រមគាត់ថាអីចឹងតែម្តង?

សារ៉ុន ៖ បាទ! ខ្ញុំថាអីចឹង ព្រោះខ្ញុំឈឺ ...។

ដារ៉ា ៖ ចៅក្រមឈ្មោះអី?

សារ៉ុន ៖ អត់ស្គាល់ អត់បានដឹងឈ្មោះគាត់ មកឡាន ហើយថ្ងៃហ្នឹងលោកគ្រូកូនហ្នឹង បុរី ថតឡាន ថតអីគេ អានេះលេងរករឿងថាលោកឯងមកថតឡាន វាថាមិនថតម៉េចផ្ទះខ្ញុំឪពុកខ្ញុំ ឆ្លើយវិញ អីចឹងត្រឹមត្រូវហើយ ។ ហើយលោកឯងមកនិយាយជាមួយប៉ាខ្ញុំបើប៉ាខ្ញុំមានធុរៈ គាត់ឈឺផង ហើយបើគាត់ម៉េចៗទៅ តើខ្ញុំមានអីភស្តុតាង លោកឯង

មកអត់ឆ្ងយឃុំ ស្រុកអីផង ។ មកមិនបានអីប្រាប់ឃុំឲ្យគេដឹងទៅ ហើយមកដល់សួរខ្ញុំ សួរគាត់អីចឹង ហើយកាលហ្នឹងខ្ញុំឈឺផង ។

ដារ៉ា : ហើយមកមានខ្មែរ មានបរទេស?

សារ៉ុន : ជនជាតិ ហើយនិងបកប្រែម្នាក់ ។

ដារ៉ា : អីចឹងមានតែអ្នកបកប្រែខ្មែរទេ ក្រៅពីហ្នឹងអត់មានខ្មែរយើងទេ?

សារ៉ុន : អត់មានទេ ។

ដារ៉ា : ហើយមានឆ្ងកាត់?

សារ៉ុន : អត់មានឆ្ងកាត់អ្នកណាទាំងអស់ ។

ដារ៉ា : មូលដ្ឋានអី?

សារ៉ុន : អត់រលើង ។

ដារ៉ា : មកសំដៅរកអ៊ី?

សារ៉ុន : មានគេឲ្យពីលើមក បើមិនអីចឹងស្រុក ឬក៏ពីណាឲ្យមក លើកទី៨ហើយ ។

ដានី : គាត់មកឆ្នាំណាដែរ?

សារ៉ុន : កុងអត់មានបារម្ភអីទេ យើងមិនដែលទៅធ្វើអី គ្រាន់តែយើងបម្រើការងារដោយស្មោះត្រង់ ។

អ្នកជិតខាងៈ គាត់ជាប្រជាជន១៧មេសា ដែលទេ ។

សារ៉ុន : ១៧ មេសា ។

អ្នកជិតខាងៈ ជម្លៀសមក គ្រាន់តែអ្នកចេះ សូម្បីតែ អំណាត វិញវាឲ្យនៅធ្វើការកំពង់ផែ ។

សារ៉ុន : នៅកប៉ាល់ ។

អ្នកជិតខាងៈ តែគាត់ស្ងាប់បាត់ហើយ ។

សារ៉ុន : សុទ្ធតែ១៧ មេសា...។

ដារ៉ា : ចេះអ៊ំដោយសាររឿងក្ដីហ្នឹងគេបានទំលាយជាសាធារណៈហើយកុង ទាក់ទងនឹងសំណុំរឿង ០០៣ ដែលទាក់ទងនឹងជនសង្ស័យឈ្មោះ មាស មុត នេះឯង ។ អ៊ំបានលឺទេ?

សារ៉ុន : មាស មុត នេះលឺច្រើន លឺសូរតែ មាស មុត ហ្នឹងច្រើនណាស់ ។

ដារ៉ា : អ៊ំមានបានលឺព័ត៌មានហ្នឹងទេ តាមវិទ្យុ ឬតាមទូរទស្សន៍អី ទាក់ទងនឹងបញ្ហាហ្នឹង?

សារ៉ុន : អត់ដែលលឺទេ អត់ដែលលឺទេ ។

ដារ៉ា : ព្រោះសហចៅក្រមស៊ើបអង្កេត មកលើកមុនសហចៅក្រមស៊ើបអង្កេតបរទេស មកធ្វើការស៊ើបអង្កេតហ្នឹងដោយមិនមានការយល់ព្រម ពីសហចៅក្រមស៊ើបអង្កេតខ្មែរយើងទេ

ព្រោះសំណុំរឿង០០៣ហ្នឹង មិនមានការយល់ព្រមពីខាងភាគីខ្មែរយើងទេ ប្រហែលជាអីចឹងហើយបានជាមក គេអត់មានឆ្លងកាត់ឃុំ តាមអីមក ។

សារ៉ុន : ប៉ុន្តែបើយើងនិយាយឲ្យវាពិស្តារទៅ គ្មានន័យអី ឧបមាថាខ្ញុំ គ្រាន់តែស្គាល់តែឈ្មោះ លឺតែឈ្មោះ មិនស្គាល់មុខ បានប្រយោជន៍អី... ។

ដារ៉ា : វាអាចថាសំខាន់ដែរ ដើម្បីបញ្ជាក់ថា មាស មុត ជាមេនៅកន្លែងហ្នឹង ចង់បានប៉ុណ្ណឹង ហើយឥលូវសំណុំរឿងវាចេញជាសាធារណៈហើយ ហើយសហព្រះរាជអាជ្ញាគាត់ខាងអន្តរជាតិបានចេញព័ត៌មានជាសាធារណៈ មានទីតាំងឧក្រិដ្ឋកម្មនៅកន្លែងនេះកន្លែងនោះ ជាពិសេសនៅការដ្ឋានវាយថ្មនៅស្ទឹងហាវអីចឹង ប៉ុន្តែខាងសហព្រះរាជអាជ្ញាខ្មែរយើង បានជំទាស់ថាតុលាការមិនមានសមត្ថកិច្ចក្នុងការ កាត់ទោសជនសង្ស័យទាំងអស់នេះទេ អីចឹងសំណុំរឿងហ្នឹងវានៅភាពចំរូងចំរាស់ អីចឹងហើយបានពួកខ្ញុំថ្ងៃនេះចុះមកដល់ទីតាំង ហើយសួរនាំព័ត៌មានបន្ថែម ក្រែងលោមានព័ត៌មានអីបន្ថែមផ្សេង ។

សារ៉ុន : មាស មុត ថានៅសព្វថ្ងៃ នៅយោធាទៀត ។

ដារ៉ា : បាទ!

សារ៉ុន : រួចធំទៀតមិនមែនតូចទេ ព្រោះកាលហ្នឹងការអំពាវនាវ ការសម្រុះសម្រួលត្រីភាគីយើងទីក្រុងប៉ារីសហ្នឹង យើងមានទៅធ្វើអីគេកើត ព្រោះគេចូលបម្រើការងារជាមួយយើងវិញហើយ ។

ដារ៉ា : អ៊ំមិនមានជាអារម្មណ៍ស្អី

សារ៉ុន : អត់ទេ ខ្ញុំអត់មានអារម្មណ៍អីទេ ។

ដារ៉ា : ជាមួយនឹង មាស មុត ទេ?

សារ៉ុន : អត់ទេ ខ្ញុំអត់មានអារម្មណ៍អីទេ ព្រោះគេមិនដែលស្តីថាឲ្យយើងណា៎ អត់ទាំងឃើញមុខផង ។

ដារ៉ា : ឆ្ងាយពេកម៉េច?

សារ៉ុន : មិនឆ្ងាយទេ កន្លែងគេការពារ គេមិនឲ្យយើងទៅ ឋានៈកម្មករ ប្រេងម៉ាស៊ីនប្រឡាក់អ៊ូអាប់យ៉ាំងនេះ យើងមិនដែលសួរនាំផង មកតែអាកំពិចកំប៉ុកដូចគ្នាហ្នឹង ។

ដានី : អ៊ំដែលឃើញមុខ ឌឹម ទេ?

សារ៉ុន : អត់ដែលឃើញទាំងអស់ ។ និយាយរួមប៉ុន្មានមេហ្នឹងសុទ្ធតែលាក់មុខទាំងអស់ ។

ដារ៉ា : ចុះស្អី នង ស្អី?

សារ៉ុន : នង ឆាន ។

ដារ៉ា ៖ ដែលឃើញទេអ៊ំ?

សារ៉ុន ៖ អត់ឃើញទាំងអស់ លីសួរ នង ឆាន ហ្នឹងនៅក្នុងកងពលហ្នឹងដែរ ប៉ុន្តែគាត់ក៏ក្បត់ដែល កាលហ្នឹង ។

ដានី ៖ ចុះអ៊ំដូចថាកងទ័ពដែលធ្វើកំពង់ដែហ្នឹង បើតាមអ៊ំដឹង ថាកងទ័ពហ្នឹងរបស់និរតី ឬកងទ័ព របស់បូព៌ា?

សារ៉ុន ៖ កងទ័ពហ្នឹងនៅក្នុងចំណុះឲ្យកងពលទី១ហ្នឹង អាហ្នឹងមិនមែននិរតី មិនមែនឧត្តរ មិនមែន ភូមិភាគទេ អាហ្នឹងនៅកំពង់សោមហ្នឹងម៉ង ។

ដានី ៖ បាទៗ ប៉ុន្តែកងទ័ពរបស់មជ្ឈិមហ្នឹងគេជ្រើសរើសមកពីនិរតី មកពីបូព៌ា មកបញ្ចូលគ្នា ជាកងទ័ពរបស់មជ្ឈិម អ៊ីចឹងហើយ ឪម ហ្នឹងគាត់មកពីខាងបូព៌ា មកធ្វើជាគណៈកងពល ជាមួយ មាស មុត ។ មាស មុត មកពីខាងនិរតី អ៊ីចឹងខ្ញុំចង់ដឹងថាកងទ័ពដែល កូនទាហានដែលធ្វើហ្នឹង ជាកូនទាហានរបស់ខាងបូព៌ា ឬកូនរបស់?

សារ៉ុន ៖ មិនៗ មិនដឹងទេចៅ យើងដឹងតែកងទ័ពខ្វាចគេចង់សាប់ ។

អ្នកជិតខាង៖ ទៅសួររកកងទ័ពនៅណាៗ ។

ដារ៉ា ៖ បញ្ជាការដ្ឋានកងពលទី១របស់ មាស មុត ហ្នឹងនៅកំពង់សោមនៅម្តុំណា?

សារ៉ុន ៖ ដូចជាមិននៅនេះទេ គាត់ហ្នឹងមានមួយឈ្មោះមិត្តប៉ុនៗ ហ្នឹងប្រហែលជា១៧ មេសា ក៏មិនដឹង គ្រាន់តែថាគាត់អ្នកគ្រប់គ្រង តែមនុស្សសាមញ្ញដែល ក្មេងដែលទេ ប្អូនខ្ញុំតិច តួច តែឥលូវស៊ាប់បាត់ហើយ ។

ដារ៉ា ៖ តែចង់និយាយថាកងពលរបស់ មាស មុត កងពលទី១ហ្នឹង កន្លែងបញ្ជាការដ្ឋានរបស់គេ នៅកន្លែងណា? កន្លែងមន្ទីររបស់គេ?

សារ៉ុន ៖ អាហ្នឹងដូចជានៅក្រុង បញ្ជាការដ្ឋានរបស់មេហ្នឹងបែបនៅក្រុង តែយើងមិនដឹងថានៅ កន្លែងណា អានេះសាខាគេនៅកន្លែងនេះ គ្រាន់តែកន្លែងស្តាបនាដែអ៊ីចឹង ជីកជញ្ជូនថ្ម អ៊ីចឹង ធ្វើអ៊ីចឹង ។

ដារ៉ា ៖ ព្រោះនៅកំពង់សោមហ្នឹងមានវត្ត អ៊ំមានដែលលឺព័ត៌មានទាក់ទងនឹងវត្តឥន្ទញាណទេអ៊ំ?

សារ៉ុន ៖ ជីមិនស្គាល់វត្តឥន្ទញាណ ប៉ុន្តែមិនដឹងជាវត្តអី យើងប្រចាំម៉េចយើងអត់ដឹង ។

ដារ៉ា ៖ ព្រោះវត្តហ្នឹងត្រូវបានខ្មែរក្រហមយកធ្វើជាគុក?

សារ៉ុន ៖ បាទ! លឺគេថាដែរ ។

អ្នកជិតខាង៖ យើងបែក៧៩មក ឃើញដែលនៅកន្លែងវិហារហ្នឹងមិនធ្វើគុក ។

សារ៉ុន ៖ មិនខ្មោះជាប់ជញ្ជាំង ។

អ្នកជិតខាងៈ តែឥលូវលោកធ្វើស្អាតអស់ហើយ វិហារនៅតាំ។

សារ៉ុន ៈ អត់បានដឹងទេរឿងនេះ។ ខ្ញុំមួយជីវិតខ្ញុំមិនដែលបានការងារអីទេ គ្រាន់តែថារាល់ថ្ងៃនេះរាល់បុណ្យសក្តិ ការងារ ខ្ញុំអាយុប៉ុណ្ណឹង ខ្ញុំអរគុណមិនតិចទេ ខ្ញុំនៅបម្រើការងារបានលាភសក្ការៈខ្លះៗ អីចឹងទៅណា៎ ហើយរបបហូបពីរនាក់យាយ រាល់ថ្ងៃនៅពីរនាក់យាយ កូនមានទាហាន មានដើងទឹក ហើយប៉ូលីស គ្រូ៣ មានប៉ុណ្ណឹងគ្មានស្អីមួយជីវិតគ្មានស្អីទេ រាល់ថ្ងៃ អត់មានផ្ទះអីនៅទេ ផ្ទះកូនធ្វើឲ្យតូចមួយ៤ម៉ែត្រ។

ដានី ៈ យាយឈ្មោះអី?

សារ៉ុន ៈ យាយខ្ញុំឈ្មោះ ឈូ ធា។

ដានី ៈ បាទ!

សារ៉ុន ៈ ឈូ ធា។

ដានី ៈ យាយក្រោយទេ?

សារ៉ុន ៈ បាទ! យាយក្រោយទេ យាយហ្នឹងអាពតយកទៅរៀបឲ្យ រាល់ថ្ងៃហ្នឹង។

អ្នកជិតខាងៈ យាយហ្នឹងអាពតរៀបឲ្យ។

សារ៉ុន ៈ កាលពី៧៧ ហើយយើងមិនដឹងធ្វើម៉េច យើងបានគ្នា យើងថែរក្សាគ្នាអីចឹងទៅ ចិញ្ចឹមកូនរៀងៗខ្លួន ១៣នាក់ហ្នឹងរស់ទាំងអស់។

ដារ៉ា ៈ គាត់មានកូនហើយ?

សារ៉ុន ៈ គាត់មាន៧ ងាប់១សល់៦ ហើយខ្ញុំ៤, ១០ យើងប្រសព្វជាមួយគាត់៣ទៀត ១៣ (សើច) និយាយឲ្យអស់ចោះ។

ដារ៉ា ៈ ច្រើនអ៊ំ កូនចៅច្រើន។

សារ៉ុន ៈ ហើយរស់ទាំងអស់ សួរលោកក្មួយដឹងហើយ រស់ដោយសព្វគ្រប់។

ដារ៉ា ៈ ខ្ញុំចាប់អារម្មណ៍ត្រង់ចំណុចមួយ ដែលកុងថាចៅក្រមមកសួរនាំ គាត់និយាយជាភាសាអង់គ្លេស ឬភាសារខ្មែរ?

សារ៉ុន ៈ និយាយភាសារអង់គ្លេស តែម្នាក់បកប្រែ ហើយនិយាយទៅមានទូរទស្សន៍គាត់មួយប្រដាប់ស្រូបសំលេងហ្នឹង ទូរស័ព្ទ។

ដារ៉ា ៈ អីចឹងដែរ?

សារ៉ុន ៈ ហើយគាត់មុននឹងនិយាយគាត់ប្រាប់ដែរ មួយហ្នឹង និយាយនេះចូលក្នុងទូរស័ព្ទ ហើយនិយាយភាសាគុលាការ មុននឹងនិយាយឲ្យគិតអីចឹងផង គាត់ខ្សឹបប្រាប់ខ្ញុំអីចឹងដែរ ខ្ញុំថាខ្ញុំមិនបាច់គិតច្រើនទេ ខ្ញុំនិយាយត្រង់ៗ មានស្អីនឹងអាក្រក់។

ដារ៉ា ៈ ហើយនៅពេលដែលអ៊ំមិនគិតចង់ទៅតុលាការ ទៅអ៊ីចឹង គេធ្វើម៉េចវិញទៀត?

សារ៉ុន ៈ ដល់គេថា អ៊ី! តុលាការមានលុយ កុង ខ្ញុំថាលុយក៏មិនចង់បាន ខ្ញុំខ្ពិលឡើងណាស់ តុលាការ ខ្ញុំនិយាយអ៊ីចឹង វាឈប់សួរទៅ ហើយដល់ទីបំផុតឲ្យផ្ដិតមេដាយ ធ្វើសាក្សី អ៊ីចឹង ខ្ញុំសាក្សីមែនតែខ្ញុំអត់ទៅទេ ព្រោះខ្ញុំចាស់ហើយ កាលគាត់មកហ្នឹងខ្ញុំឈឺ ខែ១ ឬ ខែ២ទេ ។

ដានីៈ ឆ្នាំហ្នឹង?

សារ៉ុន ៈ បាទ! អេ៎! ខែ១២ ខែ១១-១២ ខាងតុលាការហ្នឹង ។

ដានីៈ ឆ្នាំ២០១០?

សារ៉ុន ៈ ឆ្នាំ២០១០ ។

ដានី ៈ អ៊ំថាគេមកសួរហ្នឹង ៣-៤លើកទាំងលើកហ្នឹងហើយ?

សារ៉ុន ៈ ៤លើក មុនៗខ្ញុំសួរអ្នកនៅស្រុកទេ ធ្លាប់ដឹងការដ្ឋាន ចង់យកថ្មកន្លែងណា មានថ្ម មានគុណភាព ហ្នឹងក្រោផ្លូវការទេ ។

ដានី ៈ ២ក្រៅផ្លូវការទេ?

សារ៉ុន ៈ បាទ! តុលាការមកម្ដង ហើយតុលាការ២ដង ការទៅផ្ទះឲ្យមកខ្ញុំដែរ ហើយដល់ក្រោយមក ម៉ោ២ដង ហើយ៣ដង ចៅ ។ ខ្ញុំនឹកឃើញថាយើងចំណាស់នេះហើយ មិនមែនជាអ្នកនយោបាយ យើងជាអ្នកបម្រើប្រជាជន ហើយអ្នកកំលាំងការងារបច្ចេកទេសអ៊ីចឹង អត់មានអារម្មណ៍ថាសួរអ្នកនេះធ្វើអី អ្នកនោះធ្វើអី បើទៅដល់កោះស្លាដឹងតែងាប់តែម្ដង ទៅដឹងតែងាប់ហើយ ។

ដារ៉ា ៈ ម៉េចអ៊ីចឹងអ៊ំ?

សារ៉ុន ៈ គេវ៉ៃចោលបណ្ដើរៗអ៊ីចឹង ។

ដារ៉ា ៈ អ៊ំទៅដល់ហ្នឹងដែរ?

សារ៉ុន ៈ ទៅដល់ហ្នឹងដែរ ខ្ញុំទៅ ទៅបានប៉ុន្មានប្រហែល២ខែ វៀតណាមចូលដល់ម៉ង បើនៅតែបន្តិចទៀតងាប់ហើយ បានថាវាសំណាងល្អ ឡើងត្នោតមួយដើម... ទៅដល់ឃើញត្នោតហ្នឹងវាល្អឡើងគាប ហើយយកទឹកហូប ឡើងត្នោតបានប្រហែលជាកន្លះខែ ទឹកកំពុងតែចេញៗ ទឹកកន្លះៗបំពង់ ដល់ហើយមានវៀតណាមមកទាន់ ថាឲ្យចេញៗទៅ ទៅកំពតៗរួចខ្លួនទៅ ...ចិញ្ចឹមជីវិតពីរនាក់ប្ដីប្រពន្ធ មានបាយស៊ីណាណីអត់ ...ដាងយើងឈ្មុសឈ្មុល ពួកម៉ាក់ខ្ញុំមួយ អ៊ីចឹងដែរ ។

ដារ៉ា ៈ អ៊ីចឹងពួកខ្ញុំអរគុណលោកអ៊ំច្រើន ដែលបានផ្ដល់បទសម្ភាសន៍ ។

*សារ៉ុន ៖ បាទ!*

**ចប់**